**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៩៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# រូបសញ្ញា និងត្រារបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២២១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

**មាត្រា ១** .-

ត្រូវបានបង្កើតរូបសញ្ញា និងត្រារបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម សម្រាប់ប្រើជាផ្លូវការក្នុងដំណើរការការងាររបស់ខ្លួន។

**មាត្រា ២** .-

រូបសញ្ញារបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម មានទម្រង់ និងអត្ថន័យ ដូចខាងក្រោម៖

**១-ទម្រង់**

រូបភាពទូទៅនៃរូបសញ្ញាមានរាងមូល ព័ទ្ធដោយផ្ទៃរង្វង់ពីរ ដែលនៅក្នុងផ្នែកប្រសព្វនៃរង្វង់ទាំងពីរខាងលើមានពាក្យជាអក្សរខ្មែរ **ក្រុមប្រឹក្សាជាតិគាំពារសង្គម** និងខាងក្រោមមានពាក្យជាអក្សរអង់គ្លេស

**NATIONAL SOCIAL PROTECTION COUNCIL**។ នៅផ្នែកខាងក្នុងនៃផ្ទៃរង្វង់តូច មានរូបក្ដស់ ក្រុមមនុស្សចម្រុះ ពាក្យឆ្លាក់ជាអក្សរខ្មែរ ពាក្យជាអក្សរអង់គ្លេស និងបាច់ផ្កាភ្ញី។

**២-អត្ថន័យ**

- **ក្ដស់រចនាក្រោមទម្រង់ចម្លាក់សម័យអង្គរ៖** តំណាងឱ្យការគ្របដណ្ដប់នៃប្រព័ន្ធគាំពារសង្គម នៅព្រះរាជាណាចក្រកម្ពុជា ដែលផ្ដល់ការគាំពារទល់នឹងហានិភ័យផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **ក្រុមមនុស្សចម្រុះ៖** តំណាងឱ្យប្រជាជនក្នុងវ័យ ក្រុម ភេទ និងស្ថានភាពផ្សេងគ្នា ដែលទទួលផលពីប្រព័ន្ធគាំពារសង្គមដោយមិនមានការរើសអើង។
- **ពាក្យឆ្លាក់ជាអក្សរខ្មែរ និងអង់គ្លេស៖** តំណាងឱ្យអត្តសញ្ញាណនៃប្រព័ន្ធគាំពារសង្គមនៅកម្ពុជា។
- **បាច់ផ្កាភ្ញី៖** តំណាងឱ្យកិច្ចសហការយ៉ាងស្អិតរមួតរវាងក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធក្នុងក្របខណ្ឌក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ពលរដ្ឋ សំដៅរួមចំណែកកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព។

រូបសញ្ញារបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានទម្រង់ និងអត្ថន័យដូចខាងលើ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

**មាត្រា ៣ .-**

រូបសញ្ញារបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវបានប្រើប្រាស់សម្រាប់ករណី ដូចខាងក្រោម៖

- ដាក់តាំងនៅកន្លែងធ្វើការ
- ដាក់លើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការ
- ផ្សព្វផ្សាយ
- ធ្វើត្រា
- ធ្វើកន្លាស់ពាក់
- ធ្វើជាវត្ថុអនុស្សាវរីយ៍ជូនភ្ញៀវកិត្តិយស និង
- ប្រើប្រាស់ជាផ្លូវការផ្សេងទៀត ក្នុងករណីចាំបាច់។

**មាត្រា ៤ .-**

ក្រុមប្រឹក្សាជាតិគាំពារសង្គមមានត្រាមូលសម្រាប់ប្រតិបត្តិការងារ។

ត្រាមូលរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមមានរង្វង់ពីរ ដែលនៅចន្លោះរង្វង់ទី១ និងទី២ ដែលជាផ្ទៃប្រសព្វ ផ្នែកខាងលើមានពាក្យជាអក្សរខ្មែរ **ក្រុមប្រឹក្សាជាតិគាំពារសង្គម** រាងកោងស្របតាមផ្ទៃប្រសព្វនៃរង្វង់ទាំងពីរ និងនៅផ្នែកខាងក្រោម មានពាក្យជាអក្សរអង់គ្លេស **NATIONAL SOCIAL PROTECTION COUNCIL** រាងកោងស្របតាមផ្ទៃប្រសព្វនៃរង្វង់ទាំង២ និងមានផ្កាចន្ទន៍ចំនួន១ នៅសងខាង ចែកផ្ដាច់ពាក្យជាភាសាខ្មែរ និងពាក្យជាភាសាអង់គ្លេស។ នៅក្នុងរង្វង់តូច មានរំលេចដោយរូបក្ដស់ផ្ដល់ម្លប់លើក្រុមមនុស្សចម្រុះ នៅខាងឆ្វេងដងក្ដស់ មានពាក្យជាអក្សរខ្មែរឆ្លាក់ **គាំពារសង្គមកម្ពុជា**

នៅខាងស្ដាំជងក្លស់ និងមានរំលេចពាក្យជាអក្សរអង់គ្លេស SOCIAL PROTECTION IN CAMBODIA នៅពីក្រោមដោយមានបាច់ផ្កាភ្ញីជាទម្រ។

ត្រារបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមដែលមានទម្រង់ដូចបានចែងខាងលើ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤ កើត ខែ ចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០២៤

រូបសញ្ញារបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២៤

ត្រាមូលរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម

